រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

អត្ថបទសិក្សា ទី ១

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

នៅថ្ងៃដដែលនោះ មានសាវ័កពីរនាក់ធ្វើដំណើរឆ្ពោះទៅភូមិ-
អេម៉ាអ៊ូស ចម្ងាយប្រមាណដប់មួយគីឡូម៉ែត្រពីក្រុងយេរូសាឡឹម។
គេនិយាយគ្នាអំពីហេតុការណ៍ទាំងប៉ុន្មាន ដែលកើតមាន ។

នៅពេលដែលគេកំពុងតែពិភាក្សាគ្នា ព្រះយេស៊ូយាងមកជិតគេ
ហើយធ្វើដំណើរជាមួយគេទៅ ។ គេឃើញព្រះយេស៊ូផ្ទាល់នឹង
ភ្នែក តែគេមិនអាចស្គាល់ព្រះអង្គបានឡើយ ។ ព្រះយេស៊ូមាន
ព្រះបន្ទូលសួរគេថា÷ «អ្នករាល់គ្នាដើរបណ្តើរ ជជែកគ្នាបណ្តើរ
តើនិយាយគ្នាអំពីរឿងអ្វីហ្នឹង ? » ។

គេក៏ឈប់ដើរ ឈរស្ងៀម មានទឹកមុខស្រងូត ។ ម្នាក់ឈ្មោះ
ក្លេអូប៉ាសទូលព្រះអង្គថា÷«ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹម
ដឹងហេតុការណ៍ដែលកើតឡើង...ម្តេចក៏លោកមិនដឹង ? » ។
ព្រះអង្គសួរទៅគេថា÷ «តើរឿងអ្វី ? » ។

គេទូលឆ្លើយថា÷ «គឺរឿងលោកយេស៊ូជាអ្នកភូមិណាសារ៉ែត ។
ព្រះជាម្ចាស់ និង ប្រជាជនទាំងមូលទទួលស្គាល់ថាលោកជា
ព្យាការីមានឫទ្ធានុភាពក្នុងគ្រប់កិច្ចការដែលលោកបានធ្វើ និង
គ្រប់ពាក្យសំដីដែលលោកបានថ្លែង ។ ពួកនាយកឫជាចារ្យ និង

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ពួកមន្ត្រីរបស់យើងបានបញ្ជូនលោកទៅឱ្យគេកាត់ទោសប្រហារជីវិត ហើយគេឆ្កាងលោកផង ។ យើងបានសង្ឃឹមថា លោកនេះហើយដែលនឹងរំដោះជនជាតិអ៊ីស្រាអែល ។ តែហេតុការណ៍ទាំងនោះបានកន្លងផុតទៅបីថ្ងៃហើយ ។

...មានស្ត្រីខ្លះក្នុងចំណោមពួកយើង បានធ្វើអោយយើងឆ្ងល់យ៉ាងខ្លាំង គឺនាងនាំគ្នាទៅផ្នូរតាំងពីព្រលឹម តែមិនបានឃើញសពលោកទេ ។ នាងត្រឡប់មកវិញ រៀបរាប់ថានាងបានឃើញទេវទូតមកប្រាប់ថាលោកមានជីវិតរស់...» ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ «មនុស្សខ្វះប្រាជ្ញាអើយ ! អ្នករាល់គ្នាមិនងាយជឿពាក្យទាំងប៉ុន្មាន ដែលពួកព្យាការីបានថ្លែងសោះ ! ព្រះគ្រីស្តត្រូវតែរងទុក្ខលំបាកបែបនេះសិន មុននឹងចូលទៅទទួលសិរីរុងរឿងរបស់ព្រះអង្គ » ។

បន្ទាប់មក ព្រះយេស៊ូបកស្រាយសេចក្តីដែលមានចែងទុកអំពីព្រះអង្គ នៅក្នុងគម្ពីរទាំងមូល ចាប់ពីគម្ពីរលោកម៉ូសេរហូតដល់គម្ពីរព្យាការីទាំងអស់...

© Project WorldReach © SEAN

ព្រះអង្គគង់រួមតុជាមួយគេ ហើយយកនំប៉័ងមកកាន់ អរព្រះគុណ
ព្រះជាម្ចាស់ រួចកាច់ប្រទានអោយគេ ។ ពេលនោះ ភ្នែកគេបាន
ភ្លឺឡើង មើលព្រះអង្គស្គាល់ ប៉ុន្តែ ព្រះអង្គបាត់ពីមុខគេទៅ ។
គេនិយាយគ្នាថា÷ «កាលព្រះអង្គមានព្រះបន្ទូលមកកាន់យើង
ព្រមទាំងបកស្រាយគម្ពីរអោយយើងស្តាប់នៅតាមផ្លូវ យើងមាន
ចិត្តរំភើបយ៉ាងខ្លាំង ! » ។

គេក៏ក្រោកឡើង វិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញភ្លាម ឃើញ
ក្រុមសាវ័កទាំងដប់មួយនាក់នៅជុំគ្នាជាមួយពួកគេឯទៀតៗ គេ
ប្រាប់អ្នកទាំងពីរថា÷ «ព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញពិត
ប្រាកដមែន ហើយទ្រង់បានបង្ហាញខ្លួនអោយស៊ីម៉ូនឃើញ ! » ។

នៅពេលសាវ័កទាំងពីរនាក់កំពុងតែនិយាយរៀបរាប់ ព្រះអម្ចាស់
យាងមកគង់នៅកណ្តាលចំណោមសាវ័កទាំងអស់ ហើយមាន
ព្រះបន្ទូលថា÷ «សូមអោយអ្នករាល់គ្នាប្រកបដោយសេចក្តីសុខ-
សាន្ត » ។ គេភ័យតក់ស្លុត ញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានថា
ខ្មោចលង ។ ព្រះយេស៊ូមានព្រះបន្ទូលថា÷ ***"ហេតុអ្វីបានជាអ្នក
រាល់គ្នារន្ធត់ចិត្តដូច្នេះ ? ម្តេចក៏អ្នករាល់គ្នានៅសង្ស័យ ?*** ចូរ
មើលដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន ! ចូរស្ទាបមើល៍ ខ្មោចគ្មានសាច់

កំណត់ចំណាំ

© Project WorldReach © SEAN

- និយាយប្រាប់ក្រុមគ្រួសារ និង មិត្តភក្តិរបស់អ្នក អំពីរឿងដែលព្រះយេស៊ូលេចមកអោយពួកសិស្សព្រះអង្គឃើញក្រោយពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ដោយប្រើរូបភាព ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

គ្មានឆ្អឹងដូចខ្ញុំទេ » ។ *ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ក៏បង្ហាញព្រះហស្ត និងព្រះបាទាអោយគេឃើញ* ។

(លូកា ២៤:១៣-៥៣)

នៅក្នុងវគ្គព្រះគម្ពីរនេះ សិស្សរបស់ព្រះយេស៊ូភ័យតក់ស្លុត ហើយញ័ររន្ធត់យ៉ាងខ្លាំង ។

តើព្រះយេស៊ូមានព្រះបន្ទូលពន្យល់ពួកគេអំពីការនេះដូចម្តេចខ្លះ ? (សូមមើលឃ្លា នៅក្នុងអត្ថបទ ដែលសរសេរជាអក្សរធំៗ) ។

_____

_____

_____

_____

ចម្លើយ : អំពី « ពួកគេនៅសង្ស័យ និងនៅរន្ធត់ចិត្ត » ហើយ និងអំពី « សេចក្តីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្រៀនគេយ៉ាងច្បាស់លាស់ »។

© Project WorldReach © SEAN

ព្រះយេស៊ូបង្ហាញថាព្រះអង្គជាព្រះពិត និងជាមនុស្សពិត ដោយមានព្រះជន្មរស់ឡើងវិញ ។

សូមទន្ទេញ

«*រីឯសេចក្តីដែលមានកត់ត្រាមកនេះ គឺក្នុងគោលបំណងអោយអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជាព្រះគ្រីស្ត និងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយអោយអ្នករាល់គ្នាដែលជឿ មានជីវិតដោយរួមជាមួយព្រះអង្គ* » ។ (យ៉ូហាន ២០:៣១)

ខគម្ពីរនេះចែងថា ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញនេះជាព្រះមេស៊ី និងជាព្រះបុត្រារបស់ _____

បើអ្នកជឿលើព្រះអង្គ តើអ្នកនឹងទទួលបានអ្វី ?

តើអ្នកនៅសង្ស័យ ឬ អ្នកនឹងទទួលជឿ និងថ្វាយជីវិតរបស់អ្នកទៅព្រះយេស៊ូគ្រីស្ត ?

កិច្ចការដែលត្រូវអនុវត្ត

- សូមឈប់សង្ស័យ ហើយទទួលជឿចុះ ព្រមទាំងថ្វាយជីវិតអ្នកទាំងមូលទៅព្រះគ្រីស្ត និងធ្វើតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គផង ។
- សូមបំផ្លាញសៀវភៅ ខ្សែកថា របស់អ្វីៗដែលជាប់ទាក់ទងនឹងអំពើអាបធ្មប់ ឬ អបិយ៍ជំនឿ និងរបស់អ្វីៗដែលជាប់ទាក់ទងនឹងសាសនាក្លែងក្លាយ (ព្រះជាម្ចាស់សព្វព្រះហ-ទ័យអោយយើងមានជំនឿស្មោះអស់ពីចិត្ត) ។ ឈប់ជាប់ជំពាក់ទាក់ទងនឹងរបស់ទាំងនោះ ហើយទូលសូមអោយព្រះជាម្ចាស់រំដោះអ្នកអោយរួចពីឥទ្ធិពលអាក្រក់នៃអំពើទាំងអស់នោះ ។
- កែប្រែចិត្តគំនិតពិតប្រាកដ ដោយអនុវត្តដូចតទៅនេះ : សូមទោសមនុស្សដែលអ្នកបានធ្វើខុសលើគេ ជួយអ្នកដែលខ្វះខាត សងរបស់ដែលអ្នកបានលួចទៅអោយម្ចាស់ដើមវិញ បើអ្នកបាននិយាយភូតភរ ត្រូវសារភាព ឬ កែតម្រូវពាក្យអាក្រក់ ដែលអ្នកបាននិយាយពីអ្នកណាម្នាក់ ។ល។ ។

© Project WorldReach © SEAN